ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

**នាយកដ្ឋានព័ត៌មាន**

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពីលទ្ធផលនៃទស្សនកិច្ចរបស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅប្រទេសហុងគ្រី
# ថ្ងៃទី ១៥ ខែតុលា ឆ្នាំ២០១៩

---

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានបញ្ចប់ទស្សនកិច្ចដោយជោគជ័យនៅប្រទេសហុងគ្រី ជាកន្លែងដែលសម្តេចតេជោបានអញ្ជើញចូលរួមកិច្ចប្រជុំកំពូលប៊ុយដាប៉ែសស្តីពីទឹក លើកទី៣ (3rd BWS) នៅថ្ងៃទី ១៥ ខែតុលា នៅទីក្រុងប៊ុយដាប៉ែស។

រៀបចំឡើងក្រោមប្រធានបទ «ការទប់ស្កាត់វិបត្តិទឹក» កិច្ចប្រជុំកំពូលប៊ុយដាប៉ែសស្តីពីទឹក លើកទី៣ ត្រូវបានថ្លែងបើកដោយឯកឧត្តម យ៉ាណូស អាឌ័រ ប្រធានាធិបតីហុងគ្រី ។

ថ្លែងនៅក្នុងពិធីបើកកិច្ចប្រជុំកំពូល 3rd BWS សម្តេចតេជោនាយករដ្ឋមន្ត្រី បានគូសបញ្ជាក់ថា កម្ពុជាចាត់ទុកទឹកជា «មាសស» ដែលជាកាតាលីករយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយចីរភាព។ សម្តេចតេជោបានបញ្ជាក់បន្ថែមថា រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញជាបន្តបន្ទាប់នូវយុទ្ធសាស្ត្រចតុកោណដែលផ្តោតលើវិស័យអាទិភាពចំនួនបួនគឺៈ មនុស្ស ទឹក ភ្លើង និងថ្នល់។ ជាងនេះទៅទៀត កម្ពុជាបានចូលរួមយ៉ាងសកម្មទាំងក្នុងក្របខណ្ឌតំបន់ និងអន្តរជាតិ ចំពោះការគ្រប់គ្រងធនធានទឹក និងសកម្មភាពនានាដើម្បីការពារបរិស្ថាន រួមទាំងការទប់ស្កាត់នូវវិបត្តិទឹកផងដែរ។

សម្តេចតេជោនាយករដ្ឋមន្ត្រី បានសង្កត់ធ្ងន់ថា កម្ពុជាបានប្តេជ្ញាចិត្តយ៉ាងមុតមាំក្នុងការការពារនិងទប់ស្កាត់នូវវិបត្តិទឹក តាមរយៈការអនុវត្តនូវផែនការយុទ្ធសាស្ត្រ និងសកម្មភាពនានាដូចបង្ហាញជូនខាងក្រោមៈ

ទីមួយ បន្តពង្រឹងការអនុវត្តច្បាប់ លិខិតបទដ្ឋានគតិយុត្តិ គោលនយោបាយ និងផែនការមេស្តីពីការគ្រប់គ្រងធនធានទឹកឲ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

អាសយដ្ឋានៈ លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

**ទីពីរ** បង្កើតនិងពង្រឹងយន្តការគ្រប់គ្រងធនធានទឹកតាមអាងទន្លេ-ស្ទឹង ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដោយរៀបចំនិងអនុវត្តផែនការគ្រប់គ្រងធនធានទឹក និងអាងទន្លេ រួមមាន ការគ្រប់គ្រងធនធានទឹកបម្រើឲ្យគ្រប់វិស័យពាក់ព័ន្ធ ប្រកបដោយតុល្យភាពនិងសមធម៌ ការរៀបចំផែនទីស្ដីពីជំនន់ និងទឹកក្រោមដី ការកសាងអាងស្តុកទឹក ទំនប់ការពារទឹកជំនន់ ការពារទឹកប្រៃ ប្រព័ន្ធដោះទឹក និងឈានជាបណ្តើរៗក្នុងការធ្វើទំនើបកម្មគ្រប់ជ្រុងជ្រោយ។

**ទីបី** កសាងមូលដ្ឋានបច្ចេកទេស ធនធានមនុស្ស និងឈានទៅបង្កើតមជ្ឈមណ្ឌលគ្រប់គ្រងទិន្នន័យដែលប្រមូលផ្តុំទាំងទឹក ទាំងអាកាសធាតុ ដើម្បីវិភាគ ធ្វើអាជីវកម្ម និងផ្សព្វផ្សាយ បម្រើដល់គ្រប់វិស័យពាក់ព័ន្ធទាំងកម្រិតជាតិនិងអន្តរជាតិ ជាពិសេសបម្រើការគ្រប់គ្រង និងការអភិវឌ្ឍធនធានទឹក ការបន្តវាយតំលៃសក្តានុពល និងតម្រូវការទឹក ទាំងបរិមាណ និងគុណភាព ដើម្បីឆ្លើយតបទៅនឹងការអភិវឌ្ឍ។

**ទីបួន** ជំរុញ និងលើកទឹកចិត្តដល់វិស័យឯកជន ឲ្យចូលរួមក្នុងការអភិវឌ្ឍវិស័យធនធានទឹក ព្រមទាំងបង្កើនថវិកាជាតិ និងកៀរគរជំនួយពីស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ និងប្រទេសជាដៃគូ ដើម្បីអភិវឌ្ឍវិស័យធនធានទឹក ធានាដល់តម្រូវការទឹកក្នុងគ្រប់វិស័យពាក់ព័ន្ធ ប្រកបដោយប្រសិទ្ធភាព និងចីរភាព។

**សម្តេចតេជោនាយករដ្ឋមន្ត្រី** បានចូលជួបសម្តែងការគួរសមជាមួយឯកឧត្តម **យ៉ាណូស អាឌ័រ** ប្រធានាធិបតីហុងគ្រី។ ឯកឧត្តមប្រធានាធិបតី នឹងអញ្ជើញមកបំពេញទស្សនកិច្ចនៅប្រទេសកម្ពុជានៅចុងខែនេះ តបតាមការអញ្ជើញរបស់ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា។

នៅក្រៅកិច្ចប្រជុំកំពូល 3rd BWS **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានអនុញ្ញាតឲ្យឯកឧត្តម **លី យ៉ុង** អគ្គនាយកអង្គការអភិវឌ្ឍឧស្សាហកម្មសហប្រជាជាតិ (UNIDO) ចូលជួបសម្តែងការគួរសម ដែលក្នុងអំឡុងពេលនោះ សម្តេចតេជោបានស្នើសុំឲ្យអង្គការ UNIDO ជួយគាំទ្រទៅលើវិស័យគោលនយោបាយចំនួនពីរគឺ ៖ (១)គោលនយោបាយនាំចេញអង្ករ និង (២) គោលនយោបាយឧស្សាហកម្មឆ្នាំ ២០១៥-២០២៥៕

ថ្ងៃពុធ ០៣ រោច ខែអស្សុជ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣
រាជធានីភ្នំពេញ ថ្ងៃទី ១៦ ខែតុលា ឆ្នាំ២០១៩